**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

NATIONAL BANK OF CAMBODIA
Riel. Stability. Development.

MAS
Monetary Authority of Singapore

*ថ្ងៃអង្គារ ៩ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧*
*រាជធានីភ្នំពេញ ថ្ងៃទី១១ ខែ កក្កដា ឆ្នាំ២០២៣*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការចុះអនុស្សរណៈយោគយល់ស្តីពី "ការអភិវឌ្ឍគម្រោង Financial Transparency Corridor ( FTC )"
# រវាង
# ធនាគារជាតិនៃកម្ពុជា និងអាជ្ញាធររូបិយវត្ថុសិង្ហបុរី

១. រាជធានីភ្នំពេញ នៅថ្ងៃអង្គារ ៩ រោច ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០២៣ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ជាមួយអាជ្ញាធររូបិយវត្ថុសិង្ហបុរី ដើម្បីអភិវឌ្ឍគម្រោង Financial Transparency Corridor (FTC)។ គម្រោងនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងបង្កើតហេដ្ឋារចនាសម្ព័ន្ធឌីជីថលដើម្បីសម្រួលដល់ពាណិជ្ជកម្ម និងសេវាហិរញ្ញវត្ថុឆ្លងដែនសម្រាប់សហគ្រាសធុនតូច និងមធ្យមរវាងប្រទេសសិង្ហបុរី និងប្រទេសកម្ពុជា។

២. ក្រោមការអភិវឌ្ឍគម្រោង FTC គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅសិង្ហបុរីអាចធ្វើការវាយតម្លៃហិរញ្ញប្បទានលើអាជីវកម្មឆ្លងដែនរបស់សហគ្រាសធុនតូច និងមធ្យមនៃប្រទេសសិង្ហបុរីជាមួយសហគ្រាសធុនតូច និងមធ្យមនៃប្រទេសកម្ពុជា ដោយប្រើប្រាស់ព័ត៌មានទទួលបានពីគ្រឹះស្ថានហិរញ្ញវត្ថុនៅកម្ពុជាតាមរយៈផ្លែតហ្វម FTC។ ទន្ទឹមនឹងនេះ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលផ្តល់សេវាដល់សហគ្រាសធុនតូច និងមធ្យមនៅកម្ពុជាក៏អាចធ្វើការវាយតម្លៃហិរញ្ញប្បទាន ដោយប្រើប្រាស់ព័ត៌មានទទួលបានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅសិង្ហបុរីតាមរយៈផ្លែតហ្វម FTC ផងដែរ។ ការប្រើប្រាស់ផ្លែតហ្វម FTC នេះនឹងជួយសម្រួលដល់សហគ្រាសធុនតូច និងមធ្យមនៅប្រទេសសិង្ហបុរី និងប្រទេសកម្ពុជាពង្រីកបណ្តាញពាណិជ្ជកម្មឌីជីថលកាន់តែទូលំទូលាយតួយ៉ាងតាមរយៈបណ្តាញ Business Sans Border Proxtera និងផ្តល់ឱកាសដល់ការភ្ជាប់ទំនាក់ទំនងពាណិជ្ជកម្មកាន់តែប្រសើរក្នុងតំបន់អាស៊ាន និងតំបន់ផ្សេងៗទៀត។

៣. ការអភិវឌ្ឍផ្លែតហ្វម FTC មានគោលបំណង៖

- បង្កើតហេដ្ឋារចនាសម្ព័ន្ធឌីជីថលសម្រាប់ផ្តល់ការព្រមព្រៀងជាមុន (consent-based) ដើម្បីសម្រួលដល់ការដោះដូរព័ត៌មានរវាងគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុដែលចូលរួមក្នុងផ្លែតហ្វមនៅក្នុងប្រទេសសិង្ហបុរី និងប្រទេសកម្ពុជា លើការផ្តល់សេវាហិរញ្ញវត្ថុឆ្លងដែនដល់សហគ្រាសធុនតូច និងមធ្យម និង

- គាំទ្រការវាយតម្លៃឥណទានរបស់គ្រឹះស្ថានហិរញ្ញវត្ថុលើការផ្តល់ហិរញ្ញប្បទានពាណិជ្ជកម្ម និងការអនុលោមតាមបទប្បញ្ញត្តិស្តីពី ការប្រឆាំងការសម្អាតប្រាក់ ដើម្បីកាត់បន្ថយវិវាទពាណិជ្ជកម្ម និងហានិភ័យ។

៤. លោក Sopnendu Mohanty អគ្គនាយកប្រតិបត្តិបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអាជ្ញាធររូបិយវត្ថុសិង្ហបុរី បានលើកឡើងថា "យើងមានសេចក្តីរីករាយដែលបានសហការជាមួយធនាគារជាតិនៃកម្ពុជាលើការអភិវឌ្ឍគម្រោង FTC ដែលជាគំនិតផ្តួចផ្តើមថ្មីនៅតំបន់អាស៊ី។ គម្រោង FTC នឹងគាំទ្រដល់លំហូរពាណិជ្ជកម្មបើកចំហសម្រាប់អាជីវកម្មជាពិសេសសហគ្រាសធុនតូច និងមធ្យមតាមរយៈការពង្រឹងគុណភាពទិន្នន័យសម្រាប់ការផ្តល់សេវាហិរញ្ញវត្ថុរវាងប្រទេសសិង្ហបុរី និងប្រទេសកម្ពុជា។ ការណ៍នេះនឹងនាំឱ្យមានភាពជាដៃគូកាន់តែជិតស្និទ្ធរវាងគ្រឹះស្ថានហិរញ្ញវត្ថុរបស់ប្រទេសយើងលើការអភិវឌ្ឍផលិតផលនិងសេវាប្រកបដោយនវានុវត្តន៍ និងការអភិវឌ្ឍសេដ្ឋកិច្ចឱ្យកាន់តែរឹងមាំក្នុងសកលភាវូបនីយកម្មសេដ្ឋកិច្ចឌីជីថល។

៥. លោកជំទាវបណ្ឌិត ជា សិរី ទេសាភិបាលរង ធនាគារជាតិនៃកម្ពុជាបានមានប្រសាសន៍ថា "កាលពីខែមីនា ប្រទេសសិង្ហបុរី និងប្រទេសកម្ពុជាបានសហការលើការចែករំលែកព័ត៌មានឥណទានរបស់អតិថិជនឆ្លងដែន ដែលធ្វើឱ្យប្រជាជននៃប្រទេសទាំងពីរកាន់តែមានភាពងាយស្រួលក្នុងការទទួលបានសេវាហិរញ្ញវត្ថុពីប្រទេសនីមួយៗ។ យើងក៏មានសេចក្តីសោមនស្សក្នុងការចូលរួមអភិវឌ្ឍគម្រោង FTC ដែលធ្វើឱ្យការចែករំលែកព័ត៌មានឆ្លងដែនរបស់ប្រទេសទាំងពីរកាន់តែមានភាពទូលំទូលាយសម្រាប់ពាណិជ្ជកម្ម និងសហគ្រាសធុនតូច និងមធ្យម។ សហគ្រាសធុនតូច និងមធ្យម ជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចកម្ពុជា និងសិង្ហបុរី ហើយលទ្ធភាពក្នុងការទទួលបានហិរញ្ញប្បទានឆ្លងដែនរបស់សហគ្រាសនឹងជួយដល់ប្រតិបត្តិការរបស់អាជីវកម្ម និងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសទាំងពីរឱ្យកាន់តែរីកចម្រើន"។

## អំពីធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា ជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា គឺជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា។ បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺកំណត់ និងដឹកនាំនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សាស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយពិគ្រោះជាមួយរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនាមជាអាជ្ញាធររូបិយវត្ថុ ធនាគារជាតិនៃកម្ពុជាមានសិទ្ធិផ្តាច់មុខក្នុងការបោះផ្សាយប្រាក់រៀល ដែលជារូបិយវត្ថុជាតិ។ ធនាគារជាតិនៃកម្ពុជាជាអ្នករក្សាស្ថិរភាពរូបិយវត្ថុ។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាជាអ្នកផ្តល់និងដកហូតអាជ្ញាប័ណ្ណ ចេញបទប្បញ្ញត្តិនិងត្រួតពិនិត្យ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅកម្ពុជា។ លើសពីនេះទៀត ធនាគារជាតិនៃកម្ពុជាធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ចនិងរូបិយវត្ថុជាប្រចាំ ចេញផ្សាយរបាយការណ៍ និងព្រឹត្តិបត្រផ្សេងៗ ត្រួតពិនិត្យប្រព័ន្ធទូទាត់ជាតិ ដំឡើងតារាងស្ថិតិជញ្ជីងទូទាត់ និងចូលរួមក្នុងការគ្រប់គ្រងបំណុលក្រៅប្រទេស។

## អំពីអាជ្ញាធររូបិយវត្ថុសិង្ហបុរី

អាជ្ញាធររូបិយវត្ថុសិង្ហបុរី ជាធនាគារកណ្តាល និងជានិយ័តករហិរញ្ញវត្ថុរបស់ប្រទេសសិង្ហបុរី។ ក្នុងនាមជាធនាគារកណ្តាល អាជ្ញាធររូបិយវត្ថុសិង្ហបុរីបានលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយស្ថិរភាព និងមិនមានអតិផរណា តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុ តាមដាន និងវិភាគម៉ាក្រូសេដ្ឋកិច្ច។ អាជ្ញាធររូបិយវត្ថុសិង្ហបុរី គ្រប់គ្រងអត្រាប្តូរប្រាក់ ទុនបម្រុងបរទេសផ្លូវការ និងសន្ទនីយភាពក្នុងវិស័យធនាគារនៅប្រទេសសិង្ហបុរី។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យហិរញ្ញវត្ថុ អាជ្ញាធររូបិយវត្ថុសិង្ហបុរីលើក-កម្ពស់សុវត្ថិភាពនៃការប្រើប្រាស់សេវាហិរញ្ញវត្ថុ តាមរយៈបទប្បញ្ញត្តិប្រុងប្រយ័ត្នត្រួតពិនិត្យគ្រឹះស្ថានហិរញ្ញវត្ថុដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួននៅប្រទេសសិង្ហបុរី រួមមាន គ្រឹះស្ថានធនាគារ ក្រុមហ៊ុន-ធានារ៉ាប់រង អន្តរការីទីផ្សារមូលធន ទីប្រឹក្សាហិរញ្ញវត្ថុ និងហេដ្ឋារចនាសម្ព័ន្ធទីផ្សារហិរញ្ញវត្ថុ។ លើស-ពីនេះ អាជ្ញាធររូបិយវត្ថុសិង្ហបុរីមានកាតព្វកិច្ចគ្រប់គ្រងដំណើរការរបស់ទីផ្សារហិរញ្ញវត្ថុប្រកបដោយសុវត្ថិភាព និងផ្តល់ការអប់រំដល់វិនិយោគិន។ អាជ្ញាធររូបិយវត្ថុសិង្ហបុរីក៏សហការជាមួយឧស្សាហកម្មហិរញ្ញវត្ថុដើម្បីលើកកម្ពស់មជ្ឈមណ្ឌលហិរញ្ញវត្ថុអន្តរជាតិនៅប្រទេសសិង្ហបុរី។ អាជ្ញាធររូបិយវត្ថុសិង្ហបុរីជួយសម្រួលដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ការប្រើប្រាស់បច្ចេកវិទ្យា និងការកសាងសមត្ថភាពក្នុងឧស្សាហកម្មហិរញ្ញវត្ថុ។

**ទំនាក់ទំនង៖**

**ធនាគារជាតិនៃកម្ពុជា**

ផ្នែកទំនាក់ទំនង

ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៨០ ១៩៦

អ៊ីម៉ែល៖ nbccommuniation@nbc.gov.kh

បណ្តាញផ្សព្វផ្សាយ៖

www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial, www.twitter.com/nbccambodia, www.instagram.com/nationalbankofcambodia, www.linkedin.com/company/national-bank-of-cambodia, www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA

**អាជ្ញាធររូបិយវត្ថុសិង្ហបុរី**

Bridgitte Lee

អនុប្រធាននាយកដ្ឋាន (ទំនាក់ទំនង)

អាជ្ញាធររូបិយវត្ថុសិង្ហបុរី

Bridgittle_lee@mas.gov.sg